គាំទ្រមូលនិធិដោយ៖ SPIDER

អនុវត្តគម្រោងដោយ៖ អង្គការទិន្នន័យអំពីការអភិវឌ្ឍ Open Development Cambodia



រូបភាព៖ ក្រសួងរ៉ែ និងថាមពល

# គម្រោងការតាមដានចំណូលសាធារណៈពីឧស្សាហកម្មនិស្សារណកម្មនៅកម្ពុជា

## ទិដ្ឋភាពទូទៅ

ចំណូលមិនមែនសារពើពន្ធដែលប្រមូលបានពីវិស័យរ៉ែនៅប្រទេសកម្ពុជាក្នុងឆ្នាំ២០២០មានចំនួនប្រមាណ២១លានដុល្លារ ដែលចំណូលនេះបានបង្ហាញពីសក្តានុពលនៃចំណូលឯកជន និងសាធារណៈពីវិស័យនិស្សារណកម្ម។ ទោះជាយ៉ាងណាក៏ដោយបរិមាណទិន្នន័យសាធារណៈស្តីពីអត្ថប្រយោជន៍សេដ្ឋកិច្ច និងប្រាក់ចំណូលដែលបង្កើតដោយសកម្មភាពទាំងនេះគឺនៅមានកម្រិតនៅឡើយ ដែលនាំឱ្យមានតម្លាភាពទាបនិងកម្រិតនូវសមត្ថភាពសាធារណជននិងតួអង្គមិនមែនរដ្ឋាភិបាលក្នុងការរក្សាគណនេយ្យភាពរបស់រដ្ឋាភិបាល និងការតាមដានករណីអំពើពុករលួយក្នុងដំណើរការទាំងមូល។ ជាងនេះទៅទៀតប្រតិបត្តិការនិស្សារណកម្មជាច្រើនតែងតែប្រព្រឹត្តទៅនៅតំបន់ដាច់ស្រយាល ដែលបណ្តាលឱ្យមានការលំបាកសម្រាប់បុគ្គលក្នុងសង្គមចូលរួមក្នុងដំណើរការសម្រេចចិត្ត។ដូច្នេះតម្លាភាពទិន្នន័យបើកទូលាយគឺជាគន្លឹះសម្រាប់តាមដាន និងត្រួតពិនិត្យប្រាក់ចំណូលសាធារណៈពីឧស្សាហកម្មនិស្សារណកម្ម ហើយនេះជាមូលហេតុដែលបេសកកម្មរបស់គម្រោងរបស់យើងគឺជាការបង្កើតទំព័រព័ត៌មានទិន្នន័យថ្មីជាសាធារណៈ ដែលរួមបញ្ចូលប្រធានបទលើប្រាក់ចំណូលសាធារណៈពីឧស្សាហកម្មរ៉ែ ប្រេង និងឧស្ម័ន។ ទិន្នន័យដែលមានគុណភាពនេះនឹងធ្វើឱ្យប្រសើរឡើងនូវតម្លាភាពក្នុងវិស័យនេះ។

## គោលបំណង

### បង្កើនគណនេយ្យភាពរបស់រដ្ឋាភិបាល

ជួយឱ្យប្រជាពលរដ្ឋយល់ដឹងពីសិទ្ធិរបស់ពួកគាត់ទាក់ទងនឹងប្រាក់ចំណូលពីវិស័យឧស្សាហកម្មនិស្សារណកម្ម តាមរយៈតម្លាភាពទិន្នន័យ ដោយកែលម្អលទ្ធភាពទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋនិងភាគីពាក់ព័ន្ធចំពោះទិន្នន័យវិម្សកានិងគួរឱ្យទុកចិត្តអំពីចំណូលពីវិស័យឧស្សាហកម្មនិស្សារណកម្ម។

### បង្កើនការយល់ដឹងនិងការពិភាក្សា

ទាក់ទាញចំណាប់អារម្មណ៍ពីប្រជាពលរដ្ឋ និងលើកទឹកចិត្តឱ្យមានការជជែកដេញដោលជាសាធារណៈពីប្រាក់ចំណូលដែលបានពីវិស័យឧស្សាហកម្មនិស្សារណកម្ម តាមរយៈការបង្កើនការយល់ដឹងក្នុងចំណោមភាគីពាក់ព័ន្ធអំពីសក្តានុពលនៃទិន្នន័យសាធារណៈ ដើម្បីបង្កើនតម្លាភាពនិងគណនេយ្យភាពក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម។

**ព័ត៌មានទំនាក់ទំនង**

លោកស្រីបណ្ឌិត **KATJA SARAJEVA**

ប្រធានគ្រប់គ្រងកម្មវិធី | katja@spidercenter.org
កម្មវិធីរបស់ប្រទេសស៊ុយអែតសម្រាប់វិស័យអាយស៊ីធីនៅក្នុងតំបន់កំពុងអភិវឌ្ឍ (SPIDER)

លោក ធី ទ្រី

នាយកប្រតិបត្តិ/និពន្ធនាយក | contact@opendevcam.net
អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី)

### គាំទ្រមូលនិធិដោយ

កម្មវិធីរបស់ប្រទេសស៊ុយអែតសម្រាប់វិស័យអាយស៊ីធីនៅក្នុងតំបន់កំពុងអភិវឌ្ឍ (SPIDER)

### តំបន់គោលដៅ

គម្រោងនេះគឺជាការប្រមូលទិន្នន័យអំពីប្រតិបត្តិការរុករករ៉ែទាំងអស់នៅក្នុងប្រទេសកម្ពុជា

### អនុវត្តគម្រោងដោយ

អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី)

### រយៈពេលអនុវត្តគម្រោង

ខែវិច្ឆិកា ឆ្នាំ២០២២ ដល់ ខែតុលា ឆ្នាំ២០២៣

## សកម្មភាព

### ការចងក្រងទិន្នន័យ

- ធ្វើការវិភាគផ្នែកច្បាប់និងគោលនយោបាយដើម្បីកំណត់ប្រភេទចំណូល និងពន្ធផ្សេងៗដែលបានមកពីសម្បទាននិស្សារណកម្មក្នុងដំណាក់កាលរុករក និងធ្វើអាជីវកម្ម។
- កំណត់ប្រភពទិន្នន័យចំណូលពីវិស័យឧស្សាហកម្មនិស្សារណកម្ម (ទិន្នន័យអនឡាញនិងទិន្នន័យរបស់ក្រសួង/មន្ទីរពាក់ព័ន្ធតាមបណ្ដាខេត្ត) ដោយសហការជាមួយអង្គការ និងស្ថាប័នពាក់ព័ន្ធ។
- ប្រមូលទិន្នន័យស្ដីពីចំណូលពីសម្បទានរ៉ែ ប្រេង និងឧស្ម័ន (ការរុករកនិងការធ្វើអាជីវកម្ម)ពីភាគីពាក់ព័ន្ធរួមទាំងមន្ទីរតាមបណ្ដាខេត្តនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីររ៉ែនិងថាមពលខេត្ត។

### ការបង្កើតទំព័រព័ត៌មានទិន្នន័យថ្មី

- ចងក្រងព័ត៌មាន សេចក្ដីប្រកាស ឯកសារច្បាប់ និងឯកសារស្ដីពីប្រាក់ចំណូលពីវិស័យឧស្សាហកម្មនិស្សារណកម្ម ហើយផ្សព្វផ្សាយនៅលើគេហទំព័រអូឌីស៊ី ។
- បង្កើតនិងដាក់ឱ្យប្រើប្រាស់ទំព័រព័ត៌មានទិន្នន័យស្ដីពីប្រាក់ចំណូលសាធារណៈពីវិស័យឧស្សាហកម្មនិស្សារណកម្ម។
- រៀបចំការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដើម្បីប្រមូលមតិកែលម្អលើគំរូដើមនៃទំព័រព័ត៌មានទិន្នន័យអំពីចំណូលពីវិស័យឧស្សាហកម្មនិស្សារណកម្ម។

### សកម្មភាពផ្សព្វផ្សាយ

- រៀបចំសិក្ខាសាលាស្ដីពីការអនុវត្តល្អបំផុតសម្រាប់ការចែករំលែកទិន្នន័យស្ដីពីចំណូលពីការជីកយករ៉ែ ប្រេង និងឧស្ម័នជាមួយភាគីព័ន្ធសំខាន់ៗនាថ្នាក់ខេត្តនិងថ្នាក់ជាតិ។
- រៀបចំសិក្ខាសាលាដាក់ឱ្យប្រើប្រាស់ ដើម្បីបង្ហាញទំព័រព័ត៌មានទិន្នន័យស្ដីពីប្រាក់ចំណូលពីឧស្សាហកម្មនិស្សារណកម្មដល់វេទិកាអាយស៊ីធីនិងឌីជីថលកម្ពុជា និងវេទិកាអភិបាលកិច្ចឧស្សាហកម្មនិស្សារណកម្ម (EIGF)។

### ការផ្សព្វផ្សាយ

- រៀបចំកញ្ចប់សម្ភារៈព័ត៌មានការអប់រំនិងទំនាក់ទំនងដើម្បីបង្កើនការយល់ដឹងអំពីប្រាក់ចំណូលពីវិស័យឧស្សាហកម្មនិស្សារណកម្មក្នុងចំណោមភាគីពាក់ព័ន្ធផ្សេងៗ ក៏ដូចជាសាធារណៈជនទូទៅ ។
- ផលិតវីដេអូនិងផតខាសត៍ជាមួយអ្នកជំនាញពិភាក្សាអំពីតួនាទីនៃទិន្នន័យបើកទូលាយសម្រាប់វិស័យឧស្សាហកម្មនិស្សារណកម្ម។
- ផលិតក្រាហ្វិកព័ត៌មានអំពីការគ្រប់គ្រងប្រាក់ចំណូលលើវិស័យឧស្សាហកម្មនិស្សារណកម្មនៅកម្ពុជា។

## អ្នកទទួលផល



**២៥០** អង្គការសង្គមស៊ីវិល អង្គការបរិស្ថាន មន្ទីរបរិស្ថានតាមបណ្ដាខេត្ត សកម្មជនបរិស្ថាន អ្នកសារព័ត៌មាន



ចំនួនអ្នកចូលមើល **២.០០០**នាក់ប្រចាំខែនៅលើទំព័រព័ត៌មានទិន្នន័យស្ដីពីចំណូលសាធារណៈពីវិស័យឧស្សាហកម្មនិស្សារណកម្ម។



ប្រជាពលរដ្ឋទូទៅអាចចូលប្រើប្រាស់ទិន្នន័យថ្មីសម្រាប់ការពិគ្រោះយោបល់។